# សេចក្តីណែនាំអំពីសកម្មភាព និងការបម្រើសម្រាប់យុវវ័យ ។

*គោលការណ៍ និងសេចក្តីណែនាំទាំងនេះមានបំណងដើម្បីជួយដល់ថ្នាក់ដឹកនាំយុវវ័យ និងមជ្ឈិមវ័យ នៅពេលពួកគេប្រឹក្សាជាមួយគ្នានៅក្នុងការដាក់ផែនការឲ្យមានឱកាសបម្រើ និងសកម្មភាពកម្សាន្តក៏ការប្រកបដោយអត្ថន័យ ។ គោលការណ៍ និងសេចក្តីណែនាំទាំងនេះក៏អាចប្រើប្រាស់ជាធនធានមួយនៅក្នុងការប្រជុំក្រុមប្រឹក្សាស្តេក វួដ និងយុវវ័យផងដែរ ។*

## គោលការណ៍ទាំងឡាយ

សកម្មភាពគួរតែត្រូវបានរៀបផែនការ និងអនុវត្តដោយថ្នាក់ដឹកនាំកូរ៉ុម និងថ្នាក់ដឹកនាំក្នុងថ្នាក់ ដែលមានការគាំទ្រមកពីអ្នកផ្តល់ប្រឹក្សាមជ្ឈិមវ័យ ។ សកម្មភាពគួរតែ ៖

- ពង្រឹងសេចក្តីជំនឿរបស់ពួកជំនាន់កំពុងពេញវ័យទៅលើព្រះយេស៊ូវគ្រីស្ទ ហើយជួយកុមារ យុវវ័យ ព្រមទាំងក្រុមគ្រួសាររបស់ពួកគេឲ្យរីកចម្រើននៅលើផ្លូវនៃសេចក្តីសញ្ញា នៅពេលពួកគេជួបនឹងឧបសគ្គក្នុងជីវិត ។
- សូមជួយយុវវ័យឲ្យសម្រេចបានកិច្ចការនៃសេចក្តីសង្គ្រោះ និងភាពតម្កើងឡើង ( សូមមើល *ក្បួនខ្នាតទូទៅ ៖ ការបម្រើនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ* [ ឆ្នាំ ២០២០ ] ១.២, នៅលើគេហទំព័រ *ChurchofJesusChrist.org* ) ។
- ផ្តល់ការគាំទ្រ និងភាពជាម្ចាស់ដល់យុវវ័យ តាមរយៈការពង្រឹងសាមគ្គីភាពក្នុងកូរ៉ុម និងថ្នាក់ និងតាមរយៈការស្ថាបនាទំនាក់ទំនងរបស់ពួកគេជាមួយនឹងមិត្តភក្តិ ថ្នាក់ដឹកនាំ និងក្រុមគ្រួសារ ។
- ផ្តល់ឱកាសស្មើគ្នាឲ្យយុវវ័យបម្រើអ្នកដទៃ ព្រមទាំងអភិវឌ្ឍខាងវិញ្ញាណ ខាងសង្គម ខាងសាច់ឈាម និងខាងបញ្ញា ( សូមមើល លូកា ២:៥២ ) ។
- ផ្តល់បទពិសោធន៍ដែលជួយយុវជន និងយុវនារីឲ្យរៀបចំខ្លួនដើម្បីបំពេញតួនាទីដ៏ទេវភាពរបស់ពួកគេ ។
- ធ្វើតាមគ្រប់គោលការណ៍ និងសេចក្តីណែនាំអំពីសុវត្ថិភាព ព្រមទាំងគោលការណ៍ និងសេចក្តីណែនាំផ្សេងៗទៀត ( សូមមើល safety.ChurchofJesusChrist.org ) ។

## សេចក្តីណែនាំទាំងឡាយ

សេចក្តីណែនាំដូចខាងក្រោមអាចត្រូវបានសម្របទៅតាមស្ថានភាពក្នុងមូលដ្ឋាន នៅក្រោមការដឹកនាំរបស់ថ្នាក់ដឹកនាំក្នុងមូលដ្ឋាន ៖

- ធ្វើការបម្រើ និងសកម្មភាពប្រចាំសប្តាហ៍ បើអាចធ្វើទៅបាន ។ ការបម្រើ និងសកម្មភាពនានាអាចមិនសូវធ្វើឡើងញឹកញាប់អាស្រ័យទៅលើសេចក្តីត្រូវការ និងស្ថានភាពរបស់សមាជិកកូរ៉ុម និងថ្នាក់ ប៉ុន្តែគួរតែធ្វើយ៉ាងហោចណាស់ប្រចាំខែ ។
- បង្កើតប្រតិទិនមួយយ៉ាងហោចណាស់សម្រាប់រយៈពេលបីខែទុកជាមុន ។ ការណ៍នេះនឹងប្រាកដថា សកម្មភាពដែលមានការជម្រុញលើកស្ទួយ និងប្រកបដោយគោលបំណងផ្សេងៗ ដោយផ្អែកទៅលើគោលការណ៍ខាងលើនេះ ត្រូវបានរៀបចំដើម្បីបំពេញតាមតម្រូវការរបស់សមាជិកកូរ៉ុម និងថ្នាក់នីមួយៗ ។
- សូមស្វែងរកឱកាសឲ្យយុវវ័យផ្តល់ការបម្រើប្រកបដោយអត្ថន័យចំពោះបុគ្គលម្នាក់ៗ ក្រុមគ្រួសារ និងសហគមន៍ ។ សូមពិចារណាអំពីតម្រូវការ និងចំណាប់អារម្មណ៍របស់សមាជិកកូរ៉ុម និងថ្នាក់នីមួយៗ ខណៈពេលលើកទឹកចិត្តពួកគេឲ្យឈោងទៅជួយអ្នកដទៃក្រៅពីខ្លួនឯងផងដែរ ។
- ដោយសារសកម្មភាពរួមគ្នារវាងយុវនារី និងយុវជនមានអត្ថប្រយោជន៍ជាពិសេស សូមធ្វើសកម្មភាពទាំងនោះប្រចាំខែបើអាចធ្វើទៅបាន ។ សកម្មភាពរួមគ្នាសម្រាប់យុវវ័យដែលមានអាយុច្រើនជាងនេះអាចធ្វើឡើងកាន់តែញឹកញាប់ ។
- សូមផ្តល់ឱកាសឲ្យយុវវ័យចូលរួមក្នុងសន្និសីទ និងការបោះជំរំនានា ៖
    - យុវវ័យដែលឈានចូលដល់អាយុ ១៤ ឆ្នាំឡើងទៅ នឹងចូលរួមនៅក្នុងសន្និសីទ ដ.ក.យ ជារៀងរាល់ពីរឆ្នាំម្តង ។ សន្និសីទយុវវ័យ និងការធ្វើដំណើរអេស្វរទេះអាចធ្វើឡើងក្នុងឆ្នាំដែលសន្និសីទ ដ.ក.យ ពុំត្រូវបានធ្វើឡើង ។
    - ការបោះជំរំរបស់ក្រុមយុវនារី និងកូរ៉ុមបព្វជិតភាពអើរ៉ុនអាចត្រូវធ្វើឡើងប្រចាំឆ្នាំ ។
    - ការបោះជំរំ និងសកម្មភាពដេកយប់បន្ថែមទៀតក៏អាចត្រូវបានធ្វើឡើងផងដែរ ។ សម្រាប់យុវជន សកម្មភាព និងការបោះជំរំដេកយប់ត្រូវបានលើកទឹកចិត្តឲ្យធ្វើចំនួនបីដងទៅប្រាំមួយដងបន្ថែមទៀតជារៀងរាល់ឆ្នាំ បើអាចធ្វើទៅបាន ។
- សូមស្វែងរកគំនិតយោបល់សម្រាប់សកម្មភាពកូរ៉ុម និងថ្នាក់នៅលើគេហទំព័រ ChurchofJesusChrist.org/youth/childrenandyouth/discover ។ សូមប្រើប្រាស់ *ដើម្បីកម្លាំងនៃយុវជន* ( ឆ្នាំ ២០១១ ) ជាធនធានមួយនៅក្នុងការរៀបចំសកម្មភាព ។

## ធនធាននានា

- *ក្បួនខ្នាតទូទៅ* ជំពូកទី ១០, ១១, និង ២០
- YoungWomen.ChurchofJesusChrist.org
- AaronicPriesthoodQuorums.ChurchofJesusChrist.org

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០១៩ by Intellectual Reserve, Inc. All rights reserved. ១០/១៩. ការបកប្រែនៃ Service and Activity Guidelines for Youth Document ។ Cambodian ។
PD60009891 258 បោះពុម្ពនៅសហរដ្ឋអាមេរិក